អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Apr-2016, 11:37
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦**

**ម៉ោង ០៩:១៣នាទី**

**សវនាការលើកទី៣៩៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ
*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍

*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១៣:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះសូមជម្រាបភាគីនិងសាធារណជនថា នៅថ្ងៃនេះ អង្គជំនុំជម្រះបានកំណត់ធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-227 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ការប្រព្រឹត្តទៅលើក្រុមគោលដៅមនុស្សជាក់លាក់ចំពោះជនជាតិចាម។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-827 ប៉ុន្តែតាមការជូនដំណឹងពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញថា សាក្សីរូបនេះមិនមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ នៅថ្ងៃនេះមិនមានសាក្សីបម្រុងទេ។ សូមអរគុណលោកប្រធាន។

[០៩:១៥:២៣]

**ប្រធានអង្គជំនុំ៖**

បាទ ហើយដូច្នេះអង្គជំនុំជម្រះសូមជម្រាបជូនភាគីនិងសាធារណជនបានជ្រាបថា នៅថ្ងៃនេះអង្គជំនុំជម្រះមិនអាចធ្វើសវនាការតាមកាលវិភាគសវនាការដែលបានកំណត់ថា នៅថ្ងៃចន្ទ ទី០៤ ខែមេសា ឆ្នាំ២០១៦នេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលរហស្សនាម 2-TCW-827 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ការប្រព្រឹត្តទៅលើក្រុមគោលដៅជាក់លាក់ចំពោះជនជាតិចាម។ ដោយមូលហេតុសាក្សីដែលមានរហស្សនាម 2-TCW-827 បានប្រកែកមិនព្រមចូលមកបង្ហាញខ្លួន

ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតាមដីកាកោះហៅ។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបផងដែរថា អង្គជំនុំជម្រះនឹងចាត់វិធានការបង្ខំសាក្សីដែលមានរហស្សនាម 2-TCW-827 ឲ្យមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃស្អែក និងថ្ងៃស្អែកតាមដែលអាចធ្វើទៅបាន ដោយអនុវត្តតាមវិធានផ្ទៃក្នុងនិងបទប្បញ្ញត្តិនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

ហើយសវនាការជាបន្តទៅនេះ អង្គជំនុំជម្រះនឹងលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ដោយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះគ្រោងនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-827 ដែលបានអាក់ខានមិនព្រមមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ។

ហើយបង្គាប់អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក ខៀវ សំផន និង លោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ចូលរួមសវនាការនៅថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ០៩:១៧ នាទី)*